**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

*ថ្ងៃ ពុធ ១០ កើត ខែ កត្តិក ឆ្នាំ ថោះ បញ្ចស័ក ព.ស ២៥៦៧*

*រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០២៣*

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពីជំនួបពិភាក្សាការងាររវាងឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយឯកឧត្តម W. Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាម៉េរិក ប្រចាំព្រះរាជាណាចក្រកម្ពុជា

នៅព្រឹកថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០២៣, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលជួបពិភាក្សាការងារជាមួយឯកឧត្តម W. Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាម៉េរិក ប្រចាំព្រះរាជាណាចក្រកម្ពុជា ដើម្បីពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការបន្ថែមទៀតរវាងប្រទេសទាំងពីរ កម្ពុជា អាម៉េរិក ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** សម្តែងការស្វាគមន៍ និងថ្លែងអំណរគុណចំពោះឯកឧត្តម W. Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាម៉េរិកប្រចាំប្រទេសកម្ពុជា និងក្រុមបេសកកម្មដែលតែងតែចូលរួមយ៉ាងសកម្មក្នុងការសម្របសម្រួល ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ទាំងក្នុងវិស័យសាធារណៈ និងឯកជន និងបានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការទាំងសេដ្ឋកិច្ច និងពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ។ ជាក់ស្តែង, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** បានជំរាបជូនអំពីគោលនយោបាយ ផែនការសកម្មភាព និងកម្មវិធីអនុវត្តជាអាទិភាពរបស់កម្ពុជា ដែលមាន **សម្តេចធិបតី** ជាប្រមុខដឹកនាំក្នុងអាណត្តិទី ៧ នៃរាជរដ្ឋាភិបាល ។ ដើម្បីបន្តសម្របសម្រួលទាក់ទាញវិនិយោគអាម៉េរិកបន្ថែមទៀត, កិច្ចពិភាក្សាបានផ្តោតលើការអនុវត្តគម្រោងរវាងរដ្ឋ និងឯកជន, កសិកម្ម, ទេសចរណ៍, អប់រំ, ពន្ធដារ, និងការប្រឆាំងការជួញដូរមនុស្ស ជាដើម ។

**ឯកឧត្តមឯកអគ្គរដ្ឋទូត** បានសម្តែងនូវការអរគុណចំពោះការស្វាគមន៍យ៉ាងកក់ក្តៅពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** និងបានកត់សម្គាល់ថា សហរដ្ឋអាម៉េរិក បានពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយកម្ពុជាលើវិស័យជាច្រើនរួមមាន÷ សេដ្ឋកិច្ច ពាណិជ្ជកម្ម សុខាភិបាល និងកសិកម្ម ក៏ដូចជាគាំទ្រដល់ការធ្វើពាណិជ្ជកម្មទ្វេភាគីដែលបានរួមចំណែកក្នុងការរក្សាស្ថិរភាពនិងវិបុលភាពសេដ្ឋកិច្ចកម្ពុជា ជាមួយតំបន់ និងពិភពលោក ។ សហរដ្ឋអាម៉េរិក គឺជាទីផ្សារនាំចេញធំមួយរបស់កម្ពុជាលើផលិតផលកម្ពុជាចម្បងៗ ដូចជា÷ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរ ជាដើម ។ សហអាម៉េរិក នឹងបន្តផ្សព្វផ្សាយដើម្បីទាក់ទាញភ្ញៀវទេសចរណ៍ និងទាក់ទាញធុរកិច្ចវិនិយោគិនអាម៉េរិក ឲ្យមកវិនិយោគនៅកម្ពុជាបន្ថែមទៀតផងដែរ ។ ជាមួយគ្នានេះ, **ឯកឧត្តមឯកអគ្គរដ្ឋទូត** ក៏បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះភាពជោគជ័យរបស់កម្ពុជាក្នុងការប្រយុទ្ធប្រឆាំងការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ កន្លងមក ។ សហអាម៉េរិក, តាមរយៈ CDC និង USAID, នៅតែបន្តគាំទ្រទៅលើវិស័យសុខាភិបាល និងសុខភាពសាធារណៈ ដើម្បីជួយកម្ពុជាក្នុងការទប់ទល់នឹងវិបត្តិជម្ងឺរាតត្បាតសកល ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏បានគូសបញ្ជាក់ជាថ្មីម្តងទៀតនូវជំហរគាំទ្ររបស់កម្ពុជាអំពីកិច្ចសហប្រតិបត្តិការនៅក្នុងវិស័យអាទិភាពដែលទាក់ទាញវិនិយោគិនពីអាម៉េរិកមកកម្ពុជាបន្ថែមទៀត ។